# **អំណាចអ្នកតា** *ពាក្យ៧*

-មានតែរូបរាងគ្មានវិញ្ញាណ　　ពោះគ្មានពោះវៀនដូចមនុស្ស
ឃើញតែផឹកស៊ីមិនឃើញជុះ　　ស៊ីទាំងឈាមខ្ទុះដូចអាបធ្មប់ ។
-ឃើញតែសំកុកគ្មានធ្វើអ្វី　　តែសម្បូរឆីទាំងថ្ងៃយប់
ញាតិមិត្តជិតឆ្ងាយក៏គោរព　　ព្រោះខ្លាចជំពប់គ្រោះអាក្រក់ ។
-មិនដែលធ្វើការឮតែឈ្មោះ　　នាមកិត្តិយសគួចឆាបឆក់
អង្គុយស្ងៀម៧លាភទាំងថ្នក់　　គេសែនផ្ទក់៧បន់អ្នកតា ។
-អ្នកតាទោះជាស្លួតឬកាច　　ក៏គង់គេខ្លាចឫទ្ធិចេស្តា
ទោះគ្មានចេះអ្វីក៏អស្ចារ្យ　　ព្រោះថាអ្នកតាខ្លាំងពូកែ ។
-អ្នកដើរទៅមកមិនរំលង　　អ្នកស្ទូច អួន មង ឬអ្នកស្រែ
អ្នកផ្សារ ចម្ការ កំពង់ផែ　　ចូលសែនហូរហែមិនហ៊ានខាន ។
-បើហ៊ានធ្វើភ្លេចឬដើរហួស　　នុំះនឹងចុកពោះឈឺចាប់ប្រាណ
ដូច្នេះត្រូវតែថ្វាយឱ្យបាន　　តិចច្រើនប៉ុន្មានសូកដុំថ្ម ។
-ហេតុអ្វីមនុស្សនៅតែឆោត　　ដុំថ្មក្រឡោតព្រួតថាល្អ
អុជធូបសំពះតមមាត់ក　　អ្នកមានអ្នកក្រត្រដរចោម ។
-អ្នកខ្លះខ្លាចពេកភ្លេចដង្ហើម　　ខ្លះភ័យសម្បើមអត់ហ៊ានផោម
ខ្លះខំដើរទាយារអាក្រោម　　ខ្លះទិញទាំងស្រោមផ្ញើអ្នកតា ។
-អ្នកខ្លះអត់លុយសែនស្ករគ្រាប់　　អ្នកខ្លះខ្លាចងាប់សែនដុល្លារ
អ្នកខ្លះខ្លាចស័យសែនសុរា　　ខ្លះម្ហូបអាហារជាគ្រឿងក្លែម ។
-អ្នកខ្លះឆ្លៀតសែនជាត្រីសាច់　　អ្នកខ្លះបួរបាច់សែនបង្អែម
អ្នកខ្លះសុំខ្លួនធ្វើម៉ែយ៉ែម　　ខ្លះលាបម្សៅក្រែមឱ្យអ្នកតា ។
-គិតទៅអ្នកតាពិតសំណាង　　ទោះក្មេងក្មាងក៏គេមិនថា
គេកាន់តែខ្លបខ្លាចរអារ　　ថែមអង្វរថាកុំប្រកាន់ ។
-ការពិតអ្នកតាមនុស្សសាងមក　　ម្តេចគេបែរភ្នកធ្វើចង្ហាន់
ទៅសែនដុំថ្មអាចម៍អាត្មន　　ទោះខ្មាន់កាំភ្លើងក៏ខ្លាចដែរ ។

ថ្ងៃទី២១ តុលា ២០០៦